# ធម៌សម្រាប់ចៅអធិការ

របស់

ព្រះសាសនមុនី ចៅអធិការវត្តពិភក្ខុរង្សី ក្រុងភ្នំពេញ

តែងរៀបរៀង

សម្ដេចព្រះមហាសុមេធាធិបតី (ជោតញ្ញាណោ ជ.ណ)

សង្ឃនាយក គណៈមហានិកាយ

បានពិនិត្យផ្ទៀងផ្ទាត់ត្រឹមត្រូវហើយ

ពេកក្នុងមហាសភាអនុសំវច្ឆរសន្និបាតទី ៨ ខែមគ្គសិរ

ក្នុងព្រះរាជអាណាចក្រកម្ពុជា ព.ស. ២៤៩៤

បោះពុម្ពលើកទី ២

ព.ស. ២៤៩៥ គ.ស. ១៩៥៣

ផ្សាយចេញពី

www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

# ធម៌សម្រាប់ចៅអធិការ

របស់

ព្រះសាសនមុនី

ចៅអធិការវត្តពិកទូរង្សី ក្រុងភ្នំពេញ

តែងរៀបរៀង

សម្តេចព្រះមហាសុមេធាធិបតី (ជោតញ្ញាណោ ជ.ណ.)

សង្ឃនាយក គណៈមហានិកាយ

បានពិនិត្យផ្ទៀងផ្ទាត់ ត្រឹមត្រូវហើយ

ចែកក្នុងឱកាសអនុសំវច្ឆរសន្និបាតទី ៨ នៃមន្ត្រីសង្ឃ

ក្នុងព្រះពុទ្ធអាណាចក្រកម្ពុជា ព.ស. ២៤៩៤



ព. ស. ២៤៩៤ គ. ស. ១៩៥១

# ធម៌សម្រាប់ចៅអធិការ

របស់

ព្រះសាសនមុនី

ចៅអធិការវត្តពិកទូរង្សី ក្រុងភ្នំពេញ

តែងរៀបរៀង

សម្ដេចព្រះមហាសុមេធាធិបតី (ជោតញ្ញាណោ ជ.ណ.)

សង្ឃនាយក គណៈមហានិកាយ

បានពិនិត្យផ្ទៀងផ្ទាត់ ត្រឹមត្រូវហើយ

ចែកក្នុងឱកាសអនុសំវច្ឆរសន្និបាតទី ៨ នៃមន្ទីរសង្ឃ

ក្នុងព្រះពុទ្ធអាណាចក្រកម្ពុជា ព.ស. ២៤៩៤

ព.ស. ២៤៩៤ គ.ស. ១៩៥១

# អារម្ភកថា

បុព្វហេតុដែលនាំឲ្យកើតសៀវភៅ "ធម៌សម្រាប់ចៅអធិការ" នេះឡើង ដោយមូលហេតុ ៤ យ៉ាងគឺ៖

១– ដោយឆន្ទៈរបស់ព្រះ សុវណ្ណប្បញ្ញោ សឺន-ជន់ មេគុណ វត្តត្រាវិញទីធំវិញឡុង អតីតចៅអធិការវត្តពិសីរពកម ឃុំកៀន ថាញ់ វត្តត្រាវិញ ; ចង់បានឲ្យពួកបព្វជិតក្នុងព្រះពុទ្ធសាសនា មាន របៀបរៀបរយល្អ មានចរិយាត្រឹមត្រូវ មានវសម្រាប់ប្រតិបត្តិដូចៗគ្នា ឲ្យសមតាមឋានៈជាអ្នកបួសក្នុងព្រះពុទ្ធសាសនា ឲ្យមានទិដ្ឋិយល់ឃើញ ស្របដូចគ្នា ទើបអាចបង្កើតក្រៀកសាមគ្គីធម៌ រវាងជនរួមជាតិ រួមសាសនា រីងប៉ុងបាន អាចយកយោធព្រះពុទ្ធសាសនាទីជំពាសក-សិកា ឲ្យឈាន ទៅកាន់វឌ្ឍនធម៌ សារធម៌ ដូចសព្វប្រទេសបាន ។

២– ដោយយល់ឃើញថា សៀវភៅធម៌សម្រាប់ចៅអធិការ" របស់ព្រះសាសនមុនី មាស-កង ធម្មប្បញ្ញោ ជាកជាគណៈជាន់ទោ ចៅអធិការវត្ត ពិតូរង្សី សង្កាត់លេខ ២ ក្រុងភ្នំពេញ ជាច្បាប់ល្អបំផុត កងការរៀបរយរបស់ភិក្ខុសាមណេរ ។

៣– ដោយយើងខ្ញុំទាំងឡាយ ដូចមាននាមខាងក្រោមនេះ ទុកជាកិច្ចការ ដែលត្រូវជាសិស្សានុសិស្សរបស់ព្រះតេជ-គុណមេគណ ជានគំនិតស្របគ្នាចង់បំពេញព្រះបូជ័យលោក ព្រោះលោកលេចព្រះ ជ័យទានីងសៀវភៅនេះណាស់ ។

៤– ដោយលោកយល់ឃើញថា ពួកកុលបុត្រដែលមានរបៀបរៀបរយ មានចរិយាត្រឹមត្រូវបាននោះ គេមិនតែមានច្បាប់ពិសេសសម្រាប់ជំនួយដល់វិន័យថែមទៀត ; ព្រោះមនុស្សក្នុងលោកគ្រប់ជាតិគ្រប់សាសន៍ សុទ្ធតែមានច្បាប់ជាគ្រឿងបន្ទាត់សម្រាប់អូសទាញជាគោលដ៏សំខាន់បំផុត ; ឯពួកកុលបុត្រអ្នកកាន់ព្រះពុទ្ធសាសនា បើមានច្បាប់សម្រាប់បង្ហឹកគ្រប់គ្នាហើយ រមែងមានរបៀបរៀបរយ មានចរិយាត្រឹមត្រូវ គួរជាទីតាំងបសាទសទ្ធានៃពុទ្ធសាសនិកជនទាំងឡាយ ។

មូលហេតុទាំង ៤ យ៉ាងនេះ នាំឲ្យយើងខ្ញុំទាំងឡាយ ដែលមានលោកគ្រូពហុស្សុត ហប់-ម៉ុប ធម្មតិស្សោ ស្តីទីចៅអធិការវត្តពិសី-វារាមជាមេគំនិតក្នុងការបោះពុម្ពសៀវភៅនេះ ព្រមទាំងក្រុមការ ហានខ្លះ ដែលបានចេញចាកមាតុភូមិរបស់ខ្លួនផ្សេងៗគ្នា មកនៅចំ-ឡឹងព្រៃនគរជាដើម ក្នុងពេលដែលស្រុកខេមរមាតុភូមិកើតអសន្តិសុខ តាំងពី គ.ស. ១៩៤៥ រហូតមកដល់សព្វថ្ងៃនេះ មានសេចក្តីនឹករលឹកដល់មាតុភូមិរបស់ខ្លួនពន់ពេក តែខ្លះត្រឡប់ទៅវិញបាន ខ្លះត្រឡប់ទៅវិញមិនបាន ព្រោះស្រុកខ្លះនៅដាច់ស្រយាល នៅក្នុងពួកវៀត-មិញ ; អ្នកទាំងនោះហើយដែលចង់បានជាវត្ថុមួយ កប់ទុកក្នុងព្រះពុទ្ធសាសនា ដើម្បីចារឹកនាមរបស់ខ្លួនទុកក្នុងផ្នែកនៃព្រះពុទ្ធសាសនា . ម៉ាជាក្នុង មកផ្នែកទៅតាមកម្ពុជា [illegible] ដើម្បីឲ្យ [illegible]

ចំពោះបុព្វការីដែលចាំនឹកឡាយខ្លួនទៅផង ដើម្បីប្រាថ្នាឲ្យគាត់ផងលោកប្រកប ដោយសន្តិភាព ដោយអំណាចនៃអានិសង្សនេះផង

ឯកិច្ចការបោះពុម្ពសៀវភៅនេះ ក៏ធ្លាក់លើបន្ទុកខ្ញុំករុណា (កុក្កុ គីម-ត្រៃ ខិបប្បញ្ញោ នៅវត្តពោធិវង្ស (ប៊ុន-ដុង ចឺ - ឡើង ដោយការប្រដាក់ប្រដុករបស់ព្រះតេជ-គុណមេគណ ដែលប្រគល់ឲ្យ ខ្ញុំករុណាជួយបំពេញបំណងលោកកុដិការនេះ ខ្ញុំករុណាក៏ព្រមទទួល ដោយសេចក្តីពេញចិត្ត ក្នុងឋានៈជាអ្នកទទួលបន្ទុកអំពីឃោសនាចាត់ចែង ៗ ចំណែកខាងឧបាសក-សិកាស្រុក ពិសី ក៏បានចំណាយបច្ច័យ តិចច្រើនតាមសទ្ធាជ្រះថ្លាខ្លះទៀត ដើម្បីជាថ្លៃកុដិការបោះពុម្ពសៀវភៅ នេះ, លុះធ្មុះនៃយើងខ្ញុំជាពុទ្ធបរិស័ទទាំងឡាយ បានជួបប្រសប់គ្នា ហើយ នាំឲ្យសម្រេចជាសៀវភៅនេះឡើង យ៉ាងឆាប់រហ័សតាមគោល បំណងមែន ៗ

កាលបើបច្ច័យបានគ្រប់គ្រាន់ហើយ សប្បុរសទាំងនោះ ក៏ប្រគល់ មកខ្ញុំករុណាឲ្យជួយចាត់ចែង ខ្ញុំករុណាក៏ឡើងទៅភ្នំពេញ ហើយទៅ សូមអនុញ្ញាតអំពីព្រះតេជគុណព្រះសាសនមុនីដើម្បីយកសៀវភៅនេះទៅ បោះពុម្ព លោកក៏ព្រមអនុញ្ញាតឲ្យខ្ញុំករុណាយកទៅបោះពុម្ពតាមសេចក្តី ប្រាថ្នា បោះបានចំនួន ១០០០ ក្បាល អស់ប្រាក់ . . . : . រៀល ព្រម ទាំងបានជាវត្ថុទិញសៀវភៅធម៌ការចំផ្សេង ១ ទៀត ៗ

ឯគ្រឹះនឹងសៀវភៅដែលខ្ញុំករុណាជាវទាំងអស់នេះ ខ្ញុំករុណាដាក់ទុកជាសម្បត្តិសាលាបាលីវិទ្យាល័យពិសេសកោកម សម្រាប់ប្រើប្រាស់នឹងសម្រាប់សិក្សាតាមគុលបុត្រក្នុងព្រះពុទ្ធសាសនាសិក្សាជាសាធារណ៍ ។

ឯសៀវភៅដែលបោះពុម្ពបានទាំងប៉ុន្មាននោះ យើងខ្ញុំបានប្រគេនចំពោះព្រះតេជ-គុណមេគណក្នុងពិធីបុណ្យបំផុសសេចក្តីកតញ្ញូ ចំពោះលោកនៅថ្ងៃចន្ទ ៨ កើត ខែពិសាខ ឆ្នាំម្សាញ់បញ្ចស័ក ព. ស. ២៥២៦ ត្រូវនឹងថ្ងៃទី ២០ ខែមេសា ឆ្នាំ ១៩៨៣ ដែលយើងជាសិស្សានុសិស្សផ្តុំគំនិតគ្នាធ្វើឲ្យល្អមដល់កាលវេលាក្នុងពេលនោះ នៅចំពោះព្រះភក្ត្រព្រះតេជ-គុណមេគណ ព្រមទាំងព្រះថេរានុត្ថេរៈទាំងឡាយ និងអស់លោកអ្នកសប្បុរសគ្រប់រូប ដែលបាននិមន្តនិងអញ្ជើញមកកាន់ពិធីបុណ្យដ៏ឧឡារិកនេះ ដើម្បីឲ្យលោកបានចែងតាមសព្វព្រះទ័យ ។

ទីបំផុតនេះ យើងខ្ញុំជាសិស្សានុសិស្សសូមឧទ្ទិសកុសលដែលកើតឡើងក្នុងពេលនេះ បូជាចំពោះព្រះតេជ-គុណមេគណ ដែលមានព្រះជន្មជីពនៅឡើយ ព្រមទាំងព្រះសាសនមុនី ដែលបានតែងសៀវភៅនេះ, សូមព្រះតេជ-គុណទទួលដោយក្ដុងចិត្ត ដោយពេញព្រះទ័យចំពោះខ្ញុំព្រះករុណាទាំងឡាយ ម្យ៉ាងទៀត សូមឲ្យព្រះតេជ-គុណទាំងពីរព្រះអង្គមានព្រះជន្មរស់គង់យូរ ដើម្បីបានគ្រប់ផ្ចាក់ថេរកាល នៃព្រះតេជ-គុណទាំងឡាយរៀងៗ, និងសូមបូជាចំពោះវិញ្ញាណក្ខន្ធ

របស់អតីតព្រះរាជ-គុណរមេគណ គ្រប់ព្រះអង្គ នឹងចៅអធិការវត្តពីរ
វេនកមទាំងឡាយ មានព្រះសពព្រះមុនីបញ្ញោ ហាប់-ខៀវ ដើម ព្រមទាំង
បុព្វការីជនទាំងឡាយ គ្រប់ជាន់គ្រប់ថ្នាក់ ដែលធ្វើកាលកិរិយាទៅហើយ
ក្តី ដែលនៅរស់សព្វថ្ងៃនេះក្តី, សូមឲ្យពន្លឺព្រះពុទ្ធសាសនាភ្លឺស្វាងរុង
រឿងផ្សះរស្មីពេញមណ្ឌលលោក, សូមឲ្យសាកលលោកប្រកបដោយ
សន្តិភាពតាំងពីថ្ងៃនេះតទៅ ដោយកាន់បដិញ្ញានេះ កុំបីល្អៀងឃ្លៀង
ឃ្លាតឡើយ ។

សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ
អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា
ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ ។

សូមពួកសត្វទាំងអស់ កុំមានពៀរនឹងគ្នា សូមឲ្យបានសុខ
សូមឲ្យប្រាសចាកទុក្ខ សូមកុំព្យាបាទគ្នា សូមកុំឲ្យមានសេចក្តីបៀតបៀន
ចង្អល់ចិត្ត សូមឲ្យមានអាយុវែង សូមកុំឲ្យមានរោគ សូមឲ្យបានសម្រេច
ដោយសម្បត្តិទាំងឡាយ សូមគេគ្រប់ខ្លួន ឲ្យនៅជាសុខ (តទៅ) ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។

សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្តីទុក្ខ សូមឲ្យ

ជាសត្វបាត់សេចក្តីទុក្ខទៅ, ដែលដល់ហើយនូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ, ដែលដល់ហើយនូវសេចក្តីសោក សូមឲ្យជាសត្វបាត់សេចក្តីសោកទៅ ។

## នាមអ្នកចាត់ការ

១– ពហុស្សុត ប៉ាច់ - ម៉ុប (ធម្មតិសេក្ខ) ស្ថិតនៅអធិការវត្តពិសីកេកមជាមគ្គនាយក ។

២– ភិក្ខុ គឹម - ទ្រេរ (វិបប្បញ្ញោ) នៅវត្តពោធិវ័ន្ត (ប៊ុន - ជុំង) ប៊ី - ឡុង ជាអ្នកឧបត្ថម្ភផងជាអ្នកខ្វល់ខ្វាយចាត់ចែងបោះពុម្ព ។

៣– ព្រះមហាបរិយត្តិបឋមវិជ្ជា ប៉ាច់ - សុភ័ទ្រ (ភទ្ទត្ថេរោ) វត្តពិសីកេកម

៤– ព្រះមហាបរិយត្តិបឋមវិជ្ជា កៀង - គៀង (ឥន្ទត្ថេរោ) វត្តពិសីកេកម ។

ព្រះពុទ្ធសាសនាជាពន្លឺជាតិ ។
ព្រះពុទ្ធសាសនាជាគោលអក្សរសាស្ត្រ ប្រវត្តិសាស្ត្រជាតិ ។
ព្រះពុទ្ធសាសនាជាសាសនាសម្រាប់រដ្ឋ ។

ប្រារព្ធធ្វើបុណ្យនៅថ្ងៃពុធ ៨ កើតខែពិសាខ ឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៩៦ ត្រូវនឹងថ្ងៃទី ២០ ខែមេសា ឆ្នាំ ១៩៥៣ ។

អ្នកបកម្ពក៏

ភិក្ខុ គឹម - ត្រៃ

# អារម្ភកថា

សៀវភៅនេះឲ្យឈ្មោះថា "ធម៌សម្រាប់ចៅអធិការវត្ត" ដើម្បីជាច្បាប់ពិសេស ជាជំនួយនៃសតិបញ្ញាក្នុងការគ្រប់គ្រងពួកគណៈរបស់ភិក្ខុជាចៅអធិការ, ព្រោះថាលោកអ្នកដែលទទួលតំណែងក្រសួងណាមួយ ត្រូវតែមានច្បាប់សម្រាប់ខ្លួនដោយទៀងទាត់ ដើម្បីត្រួតត្រាពិនិត្យការក្នុងក្រសួងនោះៗ ឲ្យមានរបៀបត្រឹមត្រូវតាមឧត្តមគតិរបស់ខ្លួន ដែលនាំឲ្យបានសេចក្ដីសុខចំរើន ។

ភិក្ខុអ្នកទទួលតំណែងជាចៅអធិការឬជាគ្រូសូត្រ ក៏ទុកដូចជាក្រសួងមួយក្នុងព្រះពុទ្ធសាសនាដែរ ត្រូវតែមានច្បាប់សម្រាប់ខ្លួន នឹងខានមានពុំបាន ។ ច្បាប់ដែលសំដែងក្នុងសៀវភៅនេះ មានលេខរៀងរាយៗជាច្រើនន័យ ជាអត្ថបទសម្រាប់ពិចារណាហើយប្រតិបត្តិតាម, ច្បាប់នេះទុកជាករណីយកិច្ចដ៏ថ្លៃថ្លារបស់លោកអ្នកគ្រប់គ្រងពួកគណៈទោះបីបព្វជិតឬគ្រហស្ថ ក៏ត្រូវមានច្បាប់សម្រាប់ខ្លួន ស្របរៀងៗគ្នា

ដើម្បីជាសារប្រយោជន៍ដល់វត្តអារាម ឬដល់សង្គមរបស់ប្រទេសជាតិ ។

ធម៌សម្រាប់ចៅអធិការដែលខ្ញុំបានរៀបរៀងនេះ ដោយវត្ថុបំណងចង់ឲ្យលោកអ្នកគ្រប់គ្រងវត្ត យកជាមេគំនិតទុកជាគំរូមួយបែប ដើម្បីជាតម្រាប់ក្នុងការពារថែង ត្រួតត្រា ដោយរៀបរយឲ្យបានសុខចំរើនផង ឲ្យសមតាមឋានៈរបស់ខ្លួនជាអ្នកធំផង ។

ដោយចេតនាដ៏បរិសុទ្ធរបស់ខ្ញុំដែលខំប្រឹងប្រែងសរសេររៀបរៀងច្បាប់នេះ, សូមឲ្យព្រះពុទ្ធសាសនារុងរឿង ! សូមឲ្យពុទ្ធបរិសទ័ ទាំងបព្វជិត ទាំងគ្រហស្ថ បានសុខចំរើនដូចប្រាថ្នា ! សូមឲ្យប្រទេសកម្ពុជាបានទទួលនូវសន្តិសុខតរៀងទៅ ។

*ថ្ងៃអាទិត្យ ៥ កើត ខែកត្ដិក ឆ្នាំថោះត្រីស័ក ព.ស. ២៥៣៥*

*គឺថ្ងៃ ១៨ វិច្ឆិកា ១៩៩១*

*ព្រះសាសនមុនី ធម្មប្បញ្ញា (មាស-កាង) រាជាគណៈថ្នាក់ទោ*

*ចៅអធិការវត្តពិភពថ្មីសង្កាត់លេខ ២ ក្រុងភ្នំពេញ*

# ធម៌សម្រាប់ចៅអធិការ

ភិក្ខុរូបណា ដែលគេបានសន្មត តែងតាំងឲ្យជាអ្នកគ្រប់គ្រងវត្តណាមួយ ភិក្ខុរូបនោះហៅថា «ចៅអធិការ» ឬ «ចៅអាវាស» ជាមេជាប្រធានរបស់ពួកភិក្ខុ-សាមណេរ ទោះមានអាយុកាលសមណស័ក្តិខ្ពស់-ទាប តាមលំដាប់ក្តី ឥតមានសមណស័ក្តិក្តី, កាលបើបាននាទីយ៉ាងនេះហើយ ត្រូវមានធម៌សម្រាប់ខ្លួន ជាជំនួយដ៏ច្រើនប្រការ ដើម្បីនឹងបានបរិហារ[១] ក្រុមខ្លួន ព្រមទាំងបរិហារពួកភិក្ខុ-សាមណេរឲ្យបានសេចក្តីសុខស្រួល ផុតចាកវិបត្តិភយន្តរាយ សេចក្តីក្តៅក្រហាយផ្សេងៗ ធម៌ជាជំនួយដែលនោះ គឺសេចក្តីបេះដូង នឹងសេចក្តីអង់អាច ក្នុងនាទីរបស់ខ្លួន ហើយត្រូវមានអធ្យាស្រ័យទូលាយ ប្រកបដោយមេត្តា ករុណា អាណិតអាសូរដល់អ្នកទូទៅ ប្រាសចាកសេចក្តីកំណាញ់ ឫស្យា មិនឃើញតែប្រយោជន៍ផ្ទាល់ខ្លួនមួយយ៉ាង ត្រូវជាអ្នកដឹងកាលវេលា-កាលទ្ធី ទោះបីទៅមករកគ្នាក្នុងវត្តក្តី ក្រៅវត្តក្តី ដើម្បីរក្សាធម៌សាមគ្គីកុំឲ្យបែកធ្លាយក្នុងពួកគណៈ បើទុកជាសេចក្តីប្រតិបត្តិលោក ក៏ត្រូវតាំងនៅក្នុងសេចក្តីស្ងប់ស្ងៀមរៀបរយស្មោះស្ម័គ្រ ដែលជាហេតុបណ្តុះសទ្ធាគឺជំនឿ, ឧបមា: សេចក្តីជ្រះថ្លា គួរជាទីគោរពរាប់អាន របស់អ្នកដែលនៅក្នុងវត្ត ឬ ក្នុងស្រុក តាំងពីបានគុណធម៌ជាគ្រឿងប្រដាប់ប្រដាអលង្ការផងទៀតដ៏ច្រើនន័យ

១ បរិហារ ការការពារ ឬ ត្រួតត្រា ។

ក្នុងទីនេះមិនបាននាំមកសំដែងឲ្យសព្វគ្រប់ទេ គ្រាន់តែពន្យល់ជាសេចក្ដីខ្លីៗ ជាទិដ្ឋានុគតិ ជាគោលការណ៍នៃធម៌សម្រាប់លោកជាគេហាធិការ ទើបនឹងប្រតិបត្តិតាម ឲ្យសម្រេចប្រយោជន៍សមគួរដល់ឱកាស, ដូចមានអត្ថបទដែលនាំមកពណ៌នា តាមគន្លងនៃគាថាវចនៈសុភាសិតថា ៖

អក្កោធនោ អសន្តាសី អវិកត្ថី អកុក្កុចោ
មន្តា ភាណី អនុទ្ធតោ ស វេ វាចាយតោ ភិក្ខុ ។

ប្រែថា ភិក្ខុ លោកអ្នកជាមេបា ជាប្រធានរបស់ពួកគណៈ ត្រូវមានប្រក្រតីចិត្តឲ្យធ្ងន់ មិនត្រូវឆាប់ក្រេវក្រោធ រហ័សដូចជាភ្លើងឆេះចំបើងឡើយ, ជាអ្នកមិនញាប់ញ័រចំពោះការម្មណ៍តូច·ធំ ដែលមកប៉ះពាល់ខ្លាំងខ្លួន, មិនអួតអាងឫទ្ធិអំណាច, មិនបង្កសេចក្ដីវិនាសដល់អ្នកណា, ពោលពាក្យពិរោះប្រាស្រ័យប្រកបដោយបំយក់តា ប្រើសំដីទន់ភ្លន់ផ្អែមពីរោះ, មានចិត្តនឹងធឹងមិនរាយមាយ, មានកាយវាចាសង្រួមល្អ ។

ត្រូវមានគុណធម៌ដែលជារបស់សំខាន់មួយទៀត សម្រាប់ប្រចាំអត្តភាព គួរនឹងនាំមកប្រតិស្ឋានក្នុងទីនេះ ដើម្បីជាគោលឲ្យសមតាមគាថាវចនៈ ចងទុកមកថា៖

ឧបេក្ខកោ សទា សតោ ន លោកេ មញ្ញតេ សមំ
ន វិសេសី ន និចេយ្យោ តស្ស នោ សន្តិ ឧស្សទា ។

ប្រែថា ភិក្ខុអ្នកជាមេធា ជាប្រធានរបស់ពួកគណៈ ត្រូវទុកដាក់ខ្លួននៅជាកណ្ដាលស្មើ ៗ , ត្រូវមានស្មារតីសព្វកាល, មិនត្រូវកាន់ខ្លួនថាវិសេសជាងគេ ឬស្មើនឹងគេ ឬថោកទាបជាងគេឡើយ, ត្រូវធ្វើខ្លួនឲ្យប្រាសចាកទោស ដែលជាមន្ទិលធ្វើឲ្យកើតកំរើលក្នុងប្រជុំភិក្ខុផ្សេង ៗ, មិនត្រូវលុះនៅក្នុងអគតិទាំង ៤ ប្រការ មានឆន្ទាគតិជាដើម ដែលជាហេតុធ្វើឲ្យបរិស័ទគណរបស់ខ្លួន បានសេចក្ដីខូចចិត្តឈឺចិត្ត ខូចចិត្តផ្សេងៗ ដោយសារលោកជាមេធាជាប្រធានឡើយ គឺថាភិក្ខុគួរតាំងខ្លួនឲ្យមានសណ្ដាប់ធ្នាប់ល្អ គួរជាទីគោរពតទៅ ៕

ហេតុនេះ ត្រូវបណ្ដុះព្រហ្មវិហារធម៌ទាំង ៤ ប្រការ មានមេត្តាព្រហ្មវិហារជាដើម ព្រមទាំងខន្តី សេចក្ដីអត់ធន់, វិរិយៈសេចក្ដីប្រឹងប្រែង សច្ចៈ សេចក្ដីទៀងទាត់, ឲ្យដុះដាប់នៅក្នុងចិត្តដើម្បីជាគ្រឿងត្រាមដែង ជាកម្លាំងជួយឲ្យការងារ ទំនុកបំរុងប្រតិបត្តិ នឹងបានចំរើនរីកឡើង លឿនទៅកាន់សេចក្ដីចំរើនជាលំដាប់ ៗ កាលបើបានប្រតិបត្តិយ៉ាងនេះហើយ ដែលជាអ្នកបរិហារខ្លួន ព្រមទាំងបរិហារពួកគណៈ ឲ្យបាន

ទទួលប្រយោជន៍ទាំងពីរ គឺប្រយោជន៍ក្នុងលោកនេះ និងប្រយោជន៍ក្នុងលោកខាងមុខ ឲ្យកើតសេចក្ដីសប្បាយខ្លួនទៅដល់គ្នានឹងគ្នា ទើបកប់ហៅថា ជាបុណ្យជាកុសលដ៏ធំទូលាយ សមគួរដល់ភាពរបស់ភិក្ខុ ដែលជាចៅអធិការដោយពិត ។

## នាទី និងអំណាចរបស់ចៅអធិការ

ភិក្ខុ ជាចៅអធិការ ជាអ្នកគ្រប់គ្រងវត្តអារាម ជាអ្នកមានភារៈទទួលខុសត្រូវគ្រប់យ៉ាង ក្នុងការរបស់វត្តអារាម ។

ហេតុនេះ លោកអង្គនោះ ត្រូវជាអ្នកមានភ្នែកភ្លឺ ត្រចៀកវែង ឈ្លាសប្រតិភាណយល់កិច្ចការ ក្នុងនាទីមុខក្រសួងរបស់ខ្លួន ហើយយកចិត្តទុកដាក់តាមឃ្លាំចាំមើល កិច្ចការគ្រប់យ៉ាងឲ្យស្មើ ព្រមទាំងមានឧស្សាហ៍បរិហារ ពួកក្រុមឲ្យស្ងប់ស្ងៀមរៀបរយល្អ ដើម្បីនឹងបណ្ដុះសទ្ធា ឬ រក្សាសទ្ធារបស់អ្នកស្រុកឲ្យបានចំរើនឡើង, ត្រូវលោកចៅអធិការយកចិត្តទុកដាក់ ទំនុកបម្រុងចាត់ការសិក្សារៀនសូត្រឲ្យបានចំរើនតាមកម្លាំង, ហើយត្រូវជាអ្នកមានឧបាយឲ្យឱវាទដឹកនាំប្រាប់ពន្យល់ដល់ភិក្ខុ-សាមណេរ និងក្មេងវត្ត រហូតដល់គ្រហស្ថ ប្រុសស្រី

ទាំងឡាយផង ឲ្យបានរបះរង់ក្នុងការប្រតិបត្តិផ្លូវព្រះពុទ្ធសាសនា, ជាអ្នកចេះរក្សាសេចក្ដីស្ងប់ស្ងៀមរៀបរយល្អ, មានសាមគ្គីធម៌ គឺសេចក្ដីព្រមព្រៀងចំពោះពួកមនុស្សទាំងឡាយ ជាដើម ។

ម្យ៉ាងទៀត ត្រូវឲ្យចេះក្នុងកិច្ចការជាទវកម្ម គឺការសាងសង់ថ្មី និងបដិសង្ខរណកម្ម គឺការជួសជុលសេនាសនៈផ្សេង ៗ ដែលមាននៅក្នុងវត្ត, ត្រូវចាត់ត្រូវធ្វើដោយយកចិត្តទុកដាក់ជានិច្ច ។ កាលៈបើឃើញថា "របស់ណាយ៉ាងណា គួរនឹងធ្វើទៅ យ៉ាងណាស្រួលនោះ គប្បីចាត់ចែងធ្វើឲ្យប្រព្រឹត្តទៅតាមសមគួរដល់ទីវិស័យនិងកាលៈទេសៈ", ហើយគប្បីស្ទង់មើលអំណាចនឹងកម្លាំងរបស់ខ្លួន បើអំណាចនឹងកម្លាំងនោះអាចនឹងធ្វើបានត្រឹមណា ក៏គប្បីចាត់ការធ្វើឲ្យបានសម្រេចប្រយោជន៍ក្នុងកិច្ចការតាមនាទីនោះ ៗ ។ មិនត្រូវធ្វេសប្រហែសចំណោតបណ្ដោយឲ្យកិច្ចការនោះ ៗ សាបសូន្យទៅនោះឡើយ ។ ម្យ៉ាងទៀត ទោះបីមានអ្នកណា ឬ ភិក្ខុសាមណេររូបណា ប្រាព្ធធ្វើកិច្ចការអ្វីក្នុងវត្តអារាម ដោយមិនបានសូមអនុញ្ញាតសេចក្ដីយល់ព្រមអំពីលោកចៅអធិការ គឺជាប្រព្រឹត្តធ្វើទៅតាមទំនើងចិត្តរបស់ខ្លួន រហូតដល់ប្រព្រឹត្តល្មើស បំពានបទហាម ដែលចៅអធិការបានតាំងទុកហើយដោយល្អក្ដី ក្នុងវិធីបំផុតប្រព្រឹត្តកន្លងកតិការបស់វត្តអារាម

ដែលមានឃុបឃិតគ្នាកោសទោះហើយក្ដី, ទុំនៅអធិការក្រុមមានអំណាច ក្នុងការបង្គាប់បញ្ជា ដាក់កំហុសដល់បុគ្គលដែលប្រព្រឹត្តខុសនោះ តាមបទឧក្រិដ្ឋនៃទោសកន្ទោស ដោយដាក់ទណ្ឌកម្មផ្សេងៗ មានឲ្យ ធ្វើការងារជាតួលីជាដើម ឬក៏ឲ្យទោសទណ្ឌកម្មខុតសិន ដោយបាត់ ឲ្យបានរៀនទៀនដូចអ្វីដែលដាក់ក្របញ្ចូលបកស្រាយនាទោស ដើម្បី នឹងនាំណែនាំខ្លួនប្រៀនប្រដៅកុំឲ្យប្រព្រឹត្តយ៉ាងនេះតទៅទៀតផុតទៀត ។

ឯសេចក្ដីអនុញ្ញាត ឬមិនអនុញ្ញាតនោះ ស្រេចតែលំពៅការណ៍ ដែលប្រព្រឹត្តល្មើស កំហុសនោះធ្ងន់ឬស្រាល, បើពិនិត្យទៅឃើញ ថាមិនគួរនឹងទុកឲ្យនៅក្នុងក្រុមការទៀតទេ គឺគេប្រតិបត្តិការណ៍ ឲ្យបណ្ដេញចេញពីការងារ ព្រមទាំងដកសិទ្ធិអំណាចទាំងឡាយចេញ ឲ្យស្រឡះ មានកំណត់កាលវេលាឲ្យចេញផុតអំពីកោម ឬតាមបំណង ស្រេចហើយតែលើលក្ខខណ្ឌសិទ្ធិរបស់ចៅអធិការ ដែលមានអំណាចធ្វើ បានតាមកំហុស ព្រោះចៅអធិការជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រង គ្រប់ប្រការ ។

ម្យ៉ាងទៀត ប្រសិនបើមានរឿងនោះធំហួស ក៏គប្បីស្នើសុំអាស្រ័យ តាមវិន័យអនុញ្ញាត ប្រគល់ឲ្យទៅក្រសួងការពារជាតិ ព្រោះក្នុងវត្ត អាចបង្ហើយ ១ មានលោកភិក្ខុ សាមណេរនិងក្មេងវត្ត ដែលពួកគ្រហស្ថ

អាស្រ័យនៅក្នុងវត្តរបស់វត្ត ដែលជាប់ទាក់ទងដោយផ្លូវរាជការ អាណាចក្រ ។ ហេតុនេះ ពួកបព្វជិតនិងគ្រហស្ថទាំងឡាយ គប្បីប្រតិបត្តិឲ្យសមគួរដល់ឋានៈ ដែលខ្លួននៅក្នុងសេចក្ដីគ្រប់គ្រងរបស់ចៅអធិការ កុំប្រព្រឹត្តកន្លងហួស តាមទំនងកតិកាច្បាប់សម្រាប់វត្តអារាមនោះសោះឡើយ ទើបហៅថាក្មេងវត្ត កូនសិស្សវត្ត អ្នកអាស្រ័យវត្ត បានសណ្ដាប់ធ្នាប់ល្អ ហើយបានឈ្មោះថាជាអ្នកនៅក្នុងសេចក្ដីគ្រប់គ្រងរបស់លោកចៅអធិការនោះ ៗ តទៅ, ថែមទាំងសេចក្ដីសុខសប្បាយរុងរឿងល្អក៏កើតមានឡើងគ្រប់ទិវារាត្រី ។

## ជំនួយដៃរបស់ចៅអធិការ

ក្នុងការបរិហារពួកគណៈ ឲ្យមានសេចក្ដីស្ងប់រៀបរយ ភិក្ខុ សាមណេរ គ្រប់រូប គប្បីប្រតិបត្តិតាមដូចតទៅនេះ

១– ត្រូវជាអ្នកប្រដៅងាយ ចេះគោរពរាប់អានអ្នកធំ ចេះធ្វើខ្លួនឲ្យល្មមមិនឲ្យហួសពាក្យសំដីរបស់លោក ហើយមិនត្រូវសំដែងអាកប្បកិរិយា ប្រណាំងប្រជែងអួតអាងដោយហេតុណាមួយ ។

២– ត្រូវជាអ្នកមិនពើសដៃជើង ចិត្តហ៊ានក្នុងផ្លូវទុច្ចរិត ធ្វើអាការៈដូចជាចោរ ដែលជាហេតុមិនសមគួរដល់ភេទភិក្ខុរបស់ខ្លួននោះឡើយ ។

៣– ត្រូវជាអ្នកមិនពោលពាក្យក្អកកំផ្លែងរឿររឡាះ ប្រៀង កំប្លែងខុស-មាត់ ពិសដៃពិសជើង លេងក្មេង ដូចជាពួកអ្នកលេងល្បែង ដែលជាហេតុមិនសមគួរដល់គេហដ្ឋានរបស់ខ្លួននោះឡើយ. គប្បីសំដែងអាការៈសុភាពទន់ភ្លន់ឲ្យសមរម្យជាសមណៈតទៅ ។

៤– ត្រូវជាអ្នកមិនពោលពាក្យញុះញង់ លះលើកាប់ក្រោមដល់ពួកមិត្ត ឬពោលពាក្យចាក់ដោត មុតប្រាយសុំគំនិតគ្នានឹងគ្នា ហើយលើកៗពាហរណ៍មិនប្រកបដោយធម៌វិន័យមកប្រៀបប្រដូច ធ្វើឲ្យពួកម្នាក់ពាល់គំនិតពាញដៃនោះទេ ; ចំណែកខាងខ្លួនត្រូវសំដែងអាការៈអស្ចារ្យនាំឲ្យអ្នកម្នាក់ កើតសេចក្ដីក្ដៅក្រហាយដេកមិនលក់បក់មិនហើយ យ៉ាងនេះជាដើម ។

៥– ត្រូវជាអ្នកមិនពោលពាក្យទ្រគោះ បោះបោកប្រទេចផ្ដាសា ដោយពាក្យមិនត្រូវទំនង ឬដោយគំនិតចង់ឲ្យបានលេងសប្បាយក្ដី ប្រកបដោយទោសចិត្តក្ដី ទាំងនេះក៏មិនគួរទាំងអស់ ។

៦– ត្រូវជាអ្នកមិនសន្សំដឹកនាំយករឿងគ្នានឹងគ្នាទៅនិយាយប្រាប់ប្រែងដល់ពួកអ្នកស្រុកទុកក្លួមឲ្យលេច ឬស្រុសសាយ ឬក៏ក្នុងវត្ត មិនត្រូវពោលលើកទោសតិះដៀល ដោយហេតុផ្សេងៗ ក្រៅពីសេចក្ដីពិតល្អ ដែលល្អជាផ្លូវសឲ្យឃើញថា "គេអាក្រក់ខ្លួនល្អ គេខុសខ្លួនត្រូវ,

ដោយអំណាចសេចក្ដីច្រណែន ឬស្អប់គ្នាទីផ្គាយ៉ាងនេះជាដើម» ។

៧- ត្រូវជាអ្នកគមចំពោះការប្រហារ ដោយដៃទទេដើង ឬដោយគ្រឿងសស្ត្រាវុធ ដោយហេតុសូម្បីតែមែកឈើ ឬដុំដីជាដើម ទោះបីធ្វើទោសដោយប្រាសចាកទោសក្ដី ប្រកបដោយទោសក្ដី ត្រូវហាមឃាត់ទាំងអស់ ។

៨- ត្រូវជាអ្នកមិនសំដែងកិរិយាឫកពាហ៊ឺហា ហួសហេតុ ឬពោលពាក្យសំដីផ្សេងៗ ដែលជាពាក្យបញ្ចេញឲ្យឃើញខ្លួនថា «ខ្លួនមិនកោតខ្លាច ជាការមើលងាយដល់ភាគីផ្គា ឲ្យពួកបានរកក់រង ស្រពាប់ចិត្ត តូចចិត្ត បង្អៀតបង្អល់ចិត្ត ខូចចិត្តដោយសារខ្លួន» ។

៩- ត្រូវជាអ្នកមិនញុះញង់បំបែកបំបាក់អ្នកដទៃ ឲ្យអ្នកដទៃកម្រើកចិត្តនោះទេ, មិនត្រូវព្យាយាមឲ្យតែអ្នកដទៃកើតសេចក្ដីឆ្អៀសដល់ចិត្តសម្រាញ់ ឬមួយគ្រាន់តែធ្វើដើម្បីល្បងលេងសប្បាយ ឬធ្វើដោយចិត្តកក្រើក, កការៈទាំងនេះកុំធ្វើឲ្យសោះ ។

១០- ត្រូវជាអ្នកមិនប្រព្រឹត្តធ្វើ ចំលាយរបៀបបែបផែនច្បាប់ទំលាប់ ដែលជាសេចក្ដីប្រតិបត្តិល្អ ដែលលោកអ្នកធំៗតែងតាំងទុកមកដោយបំណងល្អ ហើយខ្លួនទៅប្រព្រឹត្តចំលាយតាមបំណងសេចក្ដីបំពេញ របស់ខ្លួនពាកប មានបំបែកពួកក្រុមផ្សេងៗ ដើម្បីនឹងធ្វើឲ្យប្រេះច្បាប់ខ្លួននោះចោល ។

១១– ត្រូវជាអ្នកមិនប្រព្រឹត្តទើសទាស់ ឬមានមារយាទវៀចវេរ ប្រែផងប្រែផាង នាំឲ្យទើសគេ តម្រង់គេ ដែលជាហេតុធ្វើឲ្យខូចសេចក្តីសុខរបស់អ្នកដទៃ ដោយចេតនាក្តី ឬដើម្បីឲ្យសប្បាយចំពោះខ្លួនដែលប្រកបដោយការៈទេ, អំពើទាំងនេះត្រូវហាមដាច់ ។

១២– ត្រូវជាអ្នកមិនសំដែងខ្លួនជាមនុស្សចិត្តខ្ជាប់ចិត្តខ្ជាំង ចំពោះសត្រូវហ្វាវី ហេតុដល់គ្រោះថ្នាក់ទៅមក; គួរសង្គ្រោះ អនុគ្រោះ តាមកម្លាំងដែលខ្លួនគប្បីធ្វើបាន, ត្រូវមានការរំលឹកនៅសំគៀន ដល់ពួកគណៈដែលប្រព្រឹត្តអាក្រក់ឲ្យលះសេចក្តីអាក្រក់ចោលចេញ ដោយតាំងដែលខ្លួនគប្បីសំដែងបាន ។

សេចក្តីកុង្វហាមទាំង ១២ ខនេះ បើភិក្ខុ-សាមណេរូបណា ប្រព្រឹត្តធ្វើឲ្យកន្លងត្រង់ខណាមួយ ដែលជាចំណង់ល្អរបស់វត្ត ត្រូវមានសេចក្តីខុសតាមទោសានុទោស យ៉ាងស្រាលបំផុតត្រឹមធ្វើទណ្ឌកម្ម មានឲ្យបោសព្រាសទីធ្លាអង្គនៅដងទឹកជាដើម ទោសយ៉ាងធ្ងន់ ត្រូវបណ្តេញឲ្យចេញចាកវត្តអារាម តាមកំណត់បទវិន័យធ្លាប់ ឬក៏ឲ្យសឹកចេញចាកសិក្ខាបទ ឲ្យផុតភេទអ្នកបួសតែម្យ៉ាងប៉ុណ្ណោះ ។

# ខកតិកា

## ច្បាប់សម្រាប់វត្ត

វត្តបានបំពាក់ នូវទ្យភិក្ខុ សាមណេរទាំងឡាយ ដែលបាន លះបង់[illegible]ចូលមកបួសក្នុងព្រះពុទ្ធសាសនា, ព្រះពុទ្ធសាសនា ជាគុណសម្បត្តិរបស់អ្នកបួសគ្រប់ជាន់, កាលណាបើអ្នកបួសព្រម ព្រៀងប្រតិបត្តិឲ្យគ្រប់គ្រាន់ នឹងត្រូវបាននូវប្រយោជន៍ដ៏សមគួរផ្ទាល់ ខ្លួនគ្រប់ពេលគ្រប់វេលា, មិនតែប៉ុណ្ណោះ រាបទីនឹងញុំាងប្រយោជន៍ ឲ្យសម្រេចដល់ជនានុជន ដែលជាប់ទាក់ទងក្រសួងជាមួយផង, ហើយ សមជាអ្នកគាំពារព្រះពុទ្ធសាសនា, បើកិច្ចការឯណា យើងបានគិត ពិនិត្យសម្លឹងទៅក្នុងអនាគតក្តី បច្ចុប្បន្នក្តី អតីតក្តី ហើយមាន ប្រយោជន៍, នោះគួរតែយើងរិះរកមធ្យោបាយធ្វើ កិច្ចការនោះៗ ឲ្យកើត សេចក្តីចំរើន ព្រមទាំងរបៀបរៀបរយ, គួរតាំងនូវកតិកាទុកដើម្បី បង្ការកិច្ចការនោះៗ ឲ្យបានរឹងប៉ឹង កុំឲ្យសាបសូន្យ សេចក្តីចំរើននឹង របៀបរៀបរយ, កាលណាបើកិច្ចការទាំងឡាយនោះបានល្អ ម៉ត់ចត់ បរិសុទ្ធហើយ ក៏ជាជំនួយដល់អាយុនៃព្រះពុទ្ធសាសនា ឲ្យរឹងប៉ឹង ល្អគួរសម[illegible], [illegible]ប្រយោជន៍

ដល់ជនានុជនក្នុងព្រះនគរព្រមទាំងប្រទេសជាតិសាសនា ឈានទៅកាន់សេចក្ដីចំរើនជាលំដាប់ ។

## ខ កតិកា សេចក្ដីបញ្ញត្តិ ច្បាប់សម្រាប់វត្ត ដូចមានសេចក្ដីពោលទៅខាងមុខនេះ គឺ:

១១– កាលបើបួសជាភិក្ខុ-សាមណេរហើយ ត្រូវតាំងចិត្តសង្វាតខំសិក្សារៀនសូត្រនិងការប្រព្រឹត្តប្រតិបត្តិ តាមធម្មវិន័យ ត្រូវយកចិត្តទុកដាក់ក្នុងកិច្ចវត្តផ្សេងៗ មានឧបជ្ឈាយវត្តជាដើម ដែលជានាទីរបស់ខ្លួនត្រូវប្រព្រឹត្តត្រូវធ្វើ, ម្យ៉ាងទៀត ដូចការធ្វើវត្តនមស្ការថ្វាយបង្គំព្រះ ចំរើនព្រះបរិត្ត និងធ្វើឧបោសថកម្មតាមកាលជានិច្ច ទាំងវេនក្នុងវស្សាក្ដី ក្រៅវស្សាក្ដី កុំឲ្យខកខានទើបជាការប្រពៃ ។

១២– ត្រូវជាអ្នកគោរពចំពោះទីប្រជុំ ដូចក្នុងវេលាធ្វើវត្តថ្វាយបង្គំព្រះ ចំរើនបរិត្តនិងស្ដាប់ធម៌ទេសនាជាដើម, ត្រូវធ្វើឲ្យស្ងៀមស្ងាត់មិនត្រូវឆាន់ស្លាជក់បារី, បើមានធុរៈសម័យសុំច្បាប់ចេញចាកទីប្រជុំបាន ។

១៣– ត្រូវជាអ្នកកតញ្ញូកតវេទីចំពោះវត្តអារាម ដែលខ្លួនបានមកសំណាក់អាស្រ័យនៅសិក្សារៀនសូត្រ, គោរពបើខ្លួនដល់ពេល

ទីដ៏ឈប់នៅអាស្រ័យ ក៏ត្រូវតែសំដែងសេចក្ដីសមគួរសេចក្ដីល្អ ចំពោះវត្តឲ្យវត្តបានឃើញថា ជាអ្នកមិនមើលងាយ ឬរមិលគុណ លុបគុណវត្ត, ម្យ៉ាងទៀត កិច្ចវត្ត ឬនាទីច្បាប់សម្រាប់វត្ត ឬកិច្ចការ ដែលត្រូវធ្វើក្នុងវត្តមានកសាង ឬជួសជុលសេនាសនៈ ហើយទីង បោសសំអាតត្រូវតែធ្វើ ។

១៤– ត្រូវជាអ្នកមានសេចក្ដីស្មោះស្ម័គ្រ ត្រង់ចំពោះនាទីរបស់ខ្លួនត្រូវធ្វើខ្លួនឲ្យនៅក្រោមបង្គាប់ច្បាប់ ព្រមទាំងចេះរក្សាទឹកចិត្តលោកអ្នកធំហូតដល់ទៅចេះរក្សាសទ្ធាទឹកចិត្តរបស់ឧបាសកឧបាសិកាផង ។

១៥– ភិក្ខុ-សាមណេរប៉ុណ្ណា នៅក្នុងសេចក្ដីគ្រប់គ្រងរបស់លោកចៅអធិការ គឺថានៅក្នុងទីវត្តនេះ, បើមានបព្វជិត ឬគ្រហស្ថ ទីដកូនក្មេងជាដើម មកសុំសំណាក់អាស្រ័យនៅយូរក្ដីឆាប់ក្ដីត្រូវតែភិក្ខុសាមណេរ ជាអ្នកទទួលនោះយកសេចក្ដីបកស្នើការទីងលោកចៅអធិការជាមុនសិន, បើលោកយល់ព្រមហើយ សឹមនាំរូបអ្នកដែលមកសុំសំណាក់ មកថ្វាយបង្គំឲ្យលោកបានឃើញមុខផង, លុះដល់ពេលចេញទៅវិញក៏ត្រូវតែលា ។

១៦– ភិក្ខុ-សាមណេរប៉ុណ្ណា ឲ្យមនុស្សសំណាក់អាស្រ័យ

ហើយមិនឲ្យលោកចៅអធិការដឹងជាមុនទេ, នោះសាមីរូបអ្នកនោះគួរ ឲ្យនៅត្រូវមានទោស ដោយសេចក្តីល្មើសគន្លងច្បាប់កតិការបស់ សង្ឃ, ដែលវត្តបានចាត់ការឲ្យមានរបៀបរៀបរយ ទុកជាស្រេចហើយ ឬមួយវត្តបំរុងនឹងចាត់ការឲ្យកើតរបៀប សេចក្តីប្រតិបត្តិនេះទៀត ក៏ ត្រូវតែប្រតិបត្តិតាមឲ្យស្មើគេទៅ ។

១៧– ភិក្ខុ-សាមណេរូបណាមួយ បើមានកិច្ចទៅណា ដោយ ហោចទៅ គ្រាន់តែចេញចាកកំពីទីឧបចារវត្ត ក៏គួរតែលាលោក ចៅអធិការជាមុន, បើលោកចៅអធិការមិននៅ ក៏គួរតែគេលោកអង្គ ណា ដែលលោកចៅអធិការបានសន្មតជំនួសអង្គលោក ទើបត្រូវ តាមរបៀបធម្មវិន័យ ដើម្បីរក្សាឲ្យមានកិរិយាមារយាទ គួរជាទីពេញ ភិរម្យមើលរបស់ជនានុជនផង និងដំឡើងសាមគ្គីធម៌ឲ្យមានកម្លាំង ដើម្បីឈានឡើងទៅកាន់ឧត្តមគតិ ។

១៨.- បើសាមណេរភិក្ខុរូបណា ដែលនៅក្នុងវត្តជាមួយគ្នា មានអាពាធកើតឡើង ច្រើនឬតិចធ្ងន់ឬស្រាល ត្រូវតាំងចិត្តជួយឈឺ ឆ្អាលព្យាបាលថែទាំកុំឲ្យអស់អញ្ញលិភេញចិត្ត កុំធ្វេសប្រហែស ឡើយ [illegible]រៀមួយលុះតែមិនដឹង ។

៩- ការនៅប្រួប្រួមគ្នាច្រើន រមែងប្រទះឃើញអាកប្បកិរិយា អាការប្លុកពារបស់បុគ្គលនោះៗ ហេតុនេះអស់លោកមិនត្រូវសុខ្ញុំ ហេតុល្អិតៗ មកធ្វើជាអារម្មណ៍ ហើយបង្កើតឲ្យកើតមានឡើង ។

១០- ភិក្ខុ-សាមណេរ ដែលជាអ្នកមានសទ្ធាដល់ខ្ញុំគេង ដំរុក្ខុយ គប្បីប្រតិបត្តិតាមវគ្គតិកាច្បាប់សម្រាប់វត្តទាំង ៩ ខនេះ ឲ្យបានសព្វគ្រប់ ទើបសមជាអ្នកកាន់យកព្រះពុទ្ធសាសនាពិតមែន, ម្យ៉ាងទៀត បើភិក្ខុ-សាមណេរណាមួយធ្វើសេចក្តីល្មើសធ្វើឲ្យខុសវគ្គតិកាត្រង់ខណាមួយ នោះអ្នកសាមីខ្លួនត្រូវទទួលតាមទោសមិនត្រូវតវ៉ាឡើយ ស្រេចហើយតែលោកចៅអធិការ ឬគណៈកម្មការរបស់វត្ត ត្រូវសម្រេចធ្វើទោសដូចម្តេចធ្ងន់ ឬស្រាលយ៉ាងណា, ទៅតាមដំណើរការណ៍ដែលរូបអ្នកប្រព្រឹត្តខុសនោះ ។

---

# វិធីតាំងនាមសទ្ធិវិហារិក

ការឲ្យឈ្មោះដល់កុលបុត្រថា ឈ្មោះនេះឈ្មោះនោះជាដើម លោកហៅថា នាមបញ្ញត្តិ ។ សម្រាប់បព្វជិតព្រះពុទ្ធសាសនិក: ត្រូវប្រើនាមជាមគធភាសា ដ្បិតកម្មវាចាសម្រាប់សង្ឃកម្មទាំងពួងក្នុងព្រះពុទ្ធសាសនា សុទ្ធតែប្រើជាមគធភាសាទាំងអស់ ។ ត្រង់កន្លែងដែលត្រូវបញ្ចូលនាមបព្វជិតក្នុងកម្មវាចានោះ ទោះបីបព្វជិតជាភិក្ខុក្តី ជាសាមណេរក្តី ក៏ត្រូវប្រើនាមជាមគធភាសាគឺភាសាបាលី ទើបសូត្រកើត ។ បើយកនាមជាភាសាសម្រាប់ជាតិនីមួយៗដែលមិនមែនជាភាសាបាលីដាក់បញ្ចូលត្រង់កន្លែងនោះពុំកើតឡើយ ។ ឯការតាំងនាមនេះត្រូវនិយមប្រើតាមរបៀបសៀវភៅនាមបញ្ញត្តិ របស់សម្តេចព្រះមហាសុមេធាធិបតី (ជោតញ្ញាណោ ជ.ណ.) សង្ឃនាយកគណៈមហានិកាយ ដែលបានរៀបរៀងរួចស្រេចហើយ ។ មិនបាននាំយកមកពោលពណ៌នាក្នុងទីនេះទៀតទេ, ព្រោះសៀវភៅនាមបញ្ញត្តិនោះមានប្រាប់វិធីឲ្យតាំងនាមដល់កុលបុត្រជាបព្វជិតសព្វគ្រប់គ្នានូវភាគ ។

# នាទី ឬ មុខក្រសួងរបស់ចៅអធិការ

លោកសង្ឃណា បើគណៈការពុទ្ធបក្ស គណៈបក្ស បានសន្មតតែងតាំងឲ្យធ្វើជាចៅអធិការ សម្រាប់គ្រប់គ្រងវត្តអារាម ភិក្ខុ-សាមណេរ នោះត្រូវទទួលនាទីមុខក្រសួងរបស់ខ្លួន ហើយត្រូវប្រតិបត្តិតាមឋានៈខ្លួនដោយពេញសមត្ថភាព ។

## ឯនាទីឬមុខក្រសួងនោះមាន ១៤ ខគឺ:

១ ១– ត្រូវជាអ្នកអភិបាលវត្តអារាម ឲ្យត្រឹមត្រូវតាមវិន័យបញ្ញត្តិ រដ្ឋបញ្ញត្តិ សង្ឃបញ្ញត្តិ ផ្សេងៗ មានព្រះរាជក្រមជាដើម ។

១ ២– ត្រូវជាអ្នកចាត់ការ របៀបព្រះពុទ្ធសាសនា និងការសិក្សាឲ្យមានគុណវុឌ្ឍិ ។

១ ៣– ត្រូវជាអ្នកទំនុកបំរុងវត្តអារាម និងសម្បត្តិរបស់វត្ត កុំឲ្យវិនាសអន្តរាយ ។

១ ៤– ត្រូវជាអ្នកពិនិត្យត្រួតត្រាវត្តអារាមជានិច្ច មិនឲ្យវត្តទាំងមូលមានមនុស្សអាក្រក់ ដែលធ្វើខុសនឹងច្បាប់រដ្ឋការអាណាព្យាបាល មានខុសនឹងច្បាប់ព្រហ្មទណ្ឌជាដើម ហើយមកលួចលាក់ខ្លួននៅក្នុងបរិវេណវត្ត ។

១ ៥ – ត្រូវជាអ្នកគ្រប់គ្រងក្នុងបព្វជិត ទាំងគ្រហស្ថដែលអាស្រ័យនៅក្នុងវត្ត ដូចជាមាតាបិតាក្មេងបុត្រធុរៈធារ ។

១ ៦– ត្រូវជាអ្នករក្សាសេចក្ដីស្ងប់ស្ងាប់ ឲ្យមានរបៀបរៀបរយ ទាំងអធិករណ៍ ដែលកើតមានឡើងក្នុងវត្ត ។

១៧– ត្រូវជាអ្នកដាក់ការបង្រៀនធម្មវិន័យ ដល់បព្វជិតទាំងអប់រំឲ្យ ធម្មចារិយា ដើម្បីក្រេទឹកចិត្ត ឧបាសក ឧបាសិកា ដល់វត្តឲ្យកើតមាន សេចក្ដីជ្រះថ្លា ។

១ ៨– ត្រូវជាអ្នកបេះបាត់ការឲ្យកូនសិស្ស ក្នុងវត្តទទួលការសិក្សាប្រៀន ឲ្យមានជម្រើសវិជ្ជាត្រឹមត្រូវ តាមច្បាប់ក្រសួងសិក្សាធិការ ។

១ ៩– ត្រូវធ្វើជាបញ្ជីកូនសិស្សក្នុងវត្ត ជូនក្រសួងសិក្សាធិការ តាមច្បាប់ដែលក្រសួងបានបញ្ញត្តហើយ ។

១ ១០– ត្រូវធ្វើបញ្ជីសម្បត្តិរបស់វត្ត ទុកជាគ្រឿងសំគាល់ ឬ ជាគោលតាំង ។

១ ១១ – ត្រូវធ្វើរឿងការសារការរបស់វត្ត ទាំងគ្រហស្ថបព្វជិត ដែលនៅក្នុងវត្ត ជូនមេគណ តាមកាលបរិច្ឆេទ ។

ខ ១៦– បើភិក្ខុ-សាមណេររូបណា ដែលនៅក្នុងវត្តនោះ មានប្រាថ្នាចង់ទៅកាន់វត្តដទៃទៀត ឬ ទៅទីណា ៗ ត្រូវចេញសំបុត្របរិសុទ្ធិមួយច្បាប់ឲ្យជាគ្រឿងសំគាល់ និងលិខិតអនុញ្ញាតដើរដំណើរមួយច្បាប់ទៀតតាមព្រះសង្ឃដីកាលេខ ៦៥៦ ចុះថ្ងៃ ៥ ស៊ីយេក(កក្កដា) ឆ្នាំ ១៩៤៣ ។

ខ ១៧– បើតែចៅអធិការដឹងថា ភិក្ខុ-សាមណេររូបណាមួយទៅដើម្បីនឹងប្រព្រឹត្តអនាចារ បើមិនចេញសំបុត្រឲ្យក៏បាន តែត្រូវប្រាប់ពន្យល់ហេតុការណ៍នោះ ឲ្យភិក្ខុ-សាមណេររូបនោះៗបានដឹងផង ។

ខ ១៨– ត្រូវធ្វើបញ្ជីគ្រហស្ថបព្វជិត ដែលជាចំណុះជើងវត្ត ឬ បាននៅក្នុងវត្ត ឲ្យមានទុកក្នុងវត្តរាល់ឆ្នាំ ដើម្បីជាការស្រួលអោយល្អ ។

សេចក្ដីដូចពោលមកតាំងពី ១៤ ខនេះ គឺជានាទីឬមុខក្រសួងរបស់ចៅអធិការ ត្រូវប្រព្រឹត្ត ត្រូវធ្វើតាម ទើបសមគួរជាអ្នកទទួលតំណែងចៅអធិការ ឬ ចៅអាវាស បើមិនប្រព្រឹត្តតាមដូចន័យនេះទេ មិនសមរម្យដល់បានទុកជាចៅអធិការឡើយ ។